ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ស្តង់ដារអប្បបរមា
# មត្តេយ្យសិក្សាសហគមន៍



ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានអប់រំកុមារតូច

ឆ្នាំ២០១៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៤១ អយក. ប្រក

**ប្រកាស**
**ស្តីពី**
**ការដាក់ឱ្យប្រើស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យប្រើស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍សម្រាប់ជាប្រយោជន៍ក្នុងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២ .-**

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ រួមមាន៖

- ស្តង់ដាទី១ ការធ្វើផែនការនិងការពិនិត្យតាមដាន
- ស្តង់ដាទី២ ការបង្រៀននិងរៀន
- ស្តង់ដាទី៣ ការគ្រប់គ្រងទូទៅ
- ស្តង់ដាទី៤ ការរាយការណ៍និងព័ត៌មានត្រឡប់
- ស្តង់ដាទី៥ ទីធ្លានិងសម្ភារៈល្បែងលេងក្រៅថ្នាក់
- ស្តង់ដាទី៦ សម្ភារៈប្រើប្រាស់និងសង្ហារិម

ខ្លឹមសារទាំងស្រុងនៃស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម

# បុព្វកថា

ការសិក្សាពេញមួយជីវិត គឺជាការផ្ដើមចេញពីការធានាឱ្យបាននូវប្រសិទ្ធភាពនៃការចាប់ផ្ដើមដំបូងនៃជីវិតសិក្សាពីកម្រិតមត្តេយ្យសិក្សាឡើងទៅ។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនិងកំណត់ស្តង់ដាសម្រាប់មត្តេយ្យសិក្សា សំដៅរួមចំណែកពង្រឹងការកសាងធនធានមនុស្សប្រកបដោយសក្តានុពលក្នុងគោលដៅឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព ឆ្លើយតបយ៉ាងសមស្របនិងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាបានកំណត់ចក្ខុវិស័យប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

ការពង្រឹងគុណភាពអប់រំ ត្រូវចាប់ផ្តើមពីកម្រិតមត្តេយ្យសិក្សាឡើងទៅ ដែលជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់បន្តការសិក្សានៅកម្រិតបឋមសិក្សា និងមានការអភិវឌ្ឍឈានឡើងជាលំដាប់។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់កុមារកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំបង្កើតមត្តេយ្យសិក្សាជាច្រើននៅគ្រប់ទីកន្លែង ជាពិសេសមត្តេយ្យសិក្សាសហគមន៍ ក្នុងន័យធ្វើឱ្យសាលារៀនកាន់តែខិតជិតផ្ទះប្រជាពលរដ្ឋ ព្រមទាំងងាយស្រួលក្នុងការផ្តល់និងទទួលសេវាអប់រំផងដែរ។ ដើម្បីអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឱ្យមានស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ដែលជាមូលដ្ឋានក្នុងការជួយរដ្ឋបាលឃុំ សង្កាត់ និងគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ឱ្យចេះស្វ័យវាយតម្លៃ និងពង្រឹងការអនុវត្តខ្លួនឯង។

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ជាខ្នាតគំរូមួយសម្រាប់កំណត់វិសាលភាពនិងវាស់វែងកម្រិតនៃថ្នាក់មត្តេយ្យសិក្សាសហគមន៍ ក្នុងការធានាបាននូវប្រសិទ្ធភាពនិងគុណភាពអប់រំដែលសមស្របតាមស្ថានភាពនិងបរិបទរបស់ប្រទេសកម្ពុជា។ ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍រួមមានៈ ស្តង់ដាទី១ កំណត់អំពីការធ្វើផែនការនិងការពិនិត្យតាមដាន ស្តង់ដាទី២ កំណត់អំពីការបង្រៀននិងរៀន ស្តង់ដាទី៣ កំណត់អំពីការគ្រប់គ្រងទូទៅ ស្តង់ដាទី៤ កំណត់អំពីការរាយការណ៍និងព័ត៌មានត្រឡប់ ស្តង់ដាទី៥ កំណត់អំពីទីធ្លានិងសម្ភារៈល្បែងលេងក្រៅថ្នាក់ និងស្តង់ដាទី៦ កំណត់អំពីសម្ភារៈប្រើប្រាស់និងសង្ហារិម។ ឯកសារនេះ នឹងក្លាយជាឯកសារដ៏មានប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធ ប្រើប្រាស់ជាខ្នាតគំរូក្នុងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ដែលបានខិតខំអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី

ចូលរួមកសាងឯកសារនេះ ឱ្យបានសម្រេចជាផ្លែផ្កាឡើង ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយប្រសិទ្ធភាពនិងគុណភាព សម្រាប់កសាងសង្គមកម្ពុជាឱ្យមានវិបុលភាព និងការអភិវឌ្ឍ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# មាតិកា

**ចំណងជើង** **ទំព័រ**


ប្រកាស ...........................................

បុព្វកថា ........................................... i

មាតិកា........................................... iii

១. សេចក្ដីផ្ដើម ........................................... ១

២. គោលបំណង ........................................... ២

៣. គោលដៅ ........................................... ២

៤. ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍........................................... ៣

៤.១ ការរៀបចំស្តង់ដា ........................................... ៣

៤.២ សូចនាករនៃស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ........................................... ៣

៤.៣ កម្រិតផ្ទៀងផ្ទាត់សូចនាករ........................................... ៣

៤.៤ ការផ្ទៀងផ្ទាត់លទ្ធផល ........................................... ៣

៥. តារាងស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍........................................... ៤

ស្តង់ដាទី១ ការធ្វើផែនការនិងការពិនិត្យតាមដាន ........................................... ៤

ស្តង់ដាទី២ ការបង្រៀននិងរៀន........................................... ៥

ស្តង់ដាទី៣ ការគ្រប់គ្រងទូទៅ ........................................... ៨

ស្តង់ដាទី៤ ការរាយការណ៍និងព័ត៌មានត្រឡប់ ........................................... ៩

ស្តង់ដាទី៥ ទីធ្លានិងសម្ភារៈល្បែងលេងក្រៅថ្នាក់........................................... ១០

ស្តង់ដាទី៦ សម្ភារៈប្រើប្រាស់និងសង្ហារិម ........................................... ១១

៦. ការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍តាមស្តង់ដាអប្បបរមា........................................... ១២

៦.១ ឧបករណ៍វាយតម្លៃ ........................................... ១២

៦.២ របបនៃការវាយតម្លៃ........................................... ១២

៦.៣ គំរូនៃការវាយតម្លៃ........................................... ១៣

៧. សន្និដ្ឋាន........................................... ១៥

## ១. សេចក្តីផ្តើម

ការអភិវឌ្ឍប្រកបដោយចីរភាព ពិភពលោកបានកំណត់នូវគោលដៅសំខាន់ៗចំនួន១៧ តាមរយៈសេចក្តីប្រកាសទីក្រុង Incheon វិស័យអប់រំឆ្នាំ២០៣០ ក្នុងនោះគោលដៅទី៤ បានផ្តោតលើការធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ គោលដៅទី៤.២ បានកំណត់ថា ត្រឹមឆ្នាំ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែរក្សា ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតបឋមសិក្សា។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ បានកំណត់ថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាមនិងការការពារប្រឆាំងនិងអាជីវកម្មសេដ្ឋកិច្ចនិងកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។ ច្បាប់ស្តីពីការអប់រំ មាត្រា១៦ បានកំណត់ថា រដ្ឋត្រូវគាំពារនិងអប់រំកុមារតូច ចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ។ ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា។

រាជរដ្ឋាភិបាលបាននិងកំពុងជំរុញការអភិវឌ្ឍសាលារៀនឱ្យមានលក្ខណៈជាសាលាស្វែងរកកុមារ អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងមានបរិស្ថានសមស្របដែលជាមេត្រីរបស់កុមារ។ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ បានកំណត់ពីវិសាលភាពនៃការគាំពារនិងផ្តល់សេវាអប់រំដល់កុមារតូច ហើយក្នុងនោះក៏បានកំណត់អំពីការផ្តល់សេវាអប់រំតាមរយៈមត្តេយ្យសិក្សាសហគមន៍ផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ដោយបានកំណត់គោលនយោបាយចំនួនពីរគឺ: ១) ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់តួនាទីក្នុងការគ្រប់គ្រងដំណើរការមត្តេយ្យសិក្សាសហគមន៍ទូទាំងប្រទេសឱ្យមានប្រសិទ្ធភាព ឆ្លើយតបនឹង

តម្រូវការរៀនសូត្ររបស់កុមារប្រកបដោយគុណភាព ដើម្បីមានលក្ខណៈត្រៀមជាស្រេចសម្រាប់ការចូលរៀននៅកម្រិតបឋមសិក្សា។

អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ស្តីពីការអប់រំ និងសេចក្តីប្រកាសទីក្រុង Incheon វិស័យអប់រំឆ្នាំ២០៣០ និងជាពិសេស អនុវត្តតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍។ តើស្តង់ដាអប្បបរមាមត្តេយ្យ-សិក្សាសហគមន៍ជាអ្វី?

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពមត្តេយ្យសិក្សាសហគមន៍ ដោយផ្តោតលើការកំណត់អំពីការធ្វើផែនការ និងការពិនិត្យតាមដាន ការកំណត់អំពីគ្រូបង្រៀន ការបង្រៀន និងរៀន ការកំណត់អំពីការគ្រប់គ្រងទូទៅ ការកំណត់អំពីការរាយការណ៍និងព័ត៌មានត្រឡប់ ការកំណត់អំពីទីធ្លានិងសម្ភារៈល្បែងក្រៅថ្នាក់រៀន និងការកំណត់អំពីហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារិម ដែលរួមមានស្តង់ដាចំនួន ៦ មានសូចនាករចំនួន៣៣ សម្រាប់វាស់វែង។

## ២. គោលបំណង

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ មានគោលបំណងគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់ប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីផ្តល់ឱកាសឱ្យកុមារដែលមានអាយុចាប់ពី៣(បី)ឆ្នាំដល់ក្រោម៦(ប្រាំមួយ)ឆ្នាំ ទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន។

## ៣. គោលដៅ

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍មានគោលដៅ៖

- ពង្រឹងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រង លើការងារគ្រប់គ្រង និងដឹកនាំ និងគ្រប់អ្នកពាក់ព័ន្ធឱ្យយល់ដឹងអំពីការងារដែលមត្តេយ្យសិក្សាសហគមន៍ត្រូវធ្វើ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន និងកែលម្អគុណភាពនៃការសិក្សា
- វាស់វែងពីកម្រិតប្រសិទ្ធភាពការងារ និងគុណភាពអប់រំមត្តេយ្យសិក្សាសហគមន៍
- ធានាគុណភាព និងនិរន្តរភាពនៃមត្តេយ្យសិក្សាសហគមន៍។

## ៤. ស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍

### ៤.១ ការរៀបចំស្តង់ដា

ដើម្បីឆ្លើយតបទៅនឹងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ នៅតាមរដ្ឋបាលឃុំ សង្កាត់ ឱ្យមានគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នូវស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ចំនួន៦ ដូចខាងក្រោម៖

ស្តង់ដាទី១ ៖ ការធ្វើផែនការនិងការពិនិត្យតាមដាន

ស្តង់ដាទី២ ៖ គ្រូបង្រៀន ការបង្រៀន និងរៀន

ស្តង់ដាទី៣ ៖ ការគ្រប់គ្រងទូទៅ

ស្តង់ដាទី៤ ៖ ការរាយការណ៍និងព័ត៌មានត្រឡប់

ស្តង់ដាទី៥ ៖ ទីធ្លានិងសម្ភារៈល្បែងក្រៅថ្នាក់រៀន

ស្តង់ដាទី៦ ៖ ហេដ្ឋារចនាសម្ព័ន្ធនិងសង្ហារិម។

### ៤.២ សូចនាករនៃស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍

ក្នុងការវាស់វែងនូវស្តង់ដាទាំង៦ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវសូចនាករចំនួន៣៣ ដែលក្នុងនោះ ស្តង់ដាទី១ មាន៦សូចនាករ ស្តង់ដាទី២ មាន១២សូចនាករ ស្តង់ដាទី៣ មាន៥សូចនាករ ស្តង់ដាទី៤ មាន៤សូចនាករ ស្តង់ដាទី៥ មាន៤សូចនាករ និងស្តង់ដាទី៦ មាន២សូចនាករ។

### ៤.៣ កម្រិតផ្ទៀងផ្ទាត់សូចនាករ

កម្រិតផ្ទៀងផ្ទាត់សូចនាករ ជាការកំណត់ពីលទ្ធផលតាមបែបគុណភាពឬបរិមាណស្របតាមសូចនាករនីមួយៗ ដើម្បីចង្អុលបង្ហាញពីកម្រិតនៃការវាស់វែងការអនុវត្តសូចនាករដូចមានបង្ហាញក្នុងតារាងខាងក្រោម។

### ៤.៤ ការផ្ទៀងផ្ទាត់លទ្ធផល

ការផ្ទៀងផ្ទាត់លទ្ធផល គឺជាការវាយតម្លៃលើការអនុវត្តកម្រិតសូចនាករទាំង៣៣ ដោយដាក់ពិន្ទុផ្អែកលើភស្តុតាងនៃសូចនាករនីមួយៗដែលមានពិន្ទុសរុប៣៣ពិន្ទុ ស្មើនឹង១០០%។ ការកំណត់ថា មានឬមិនទាន់មានលក្ខណៈស្តង់ដា ត្រូវបានកំណត់ដូចខាងក្រោម៖

- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍អនុវត្តលទ្ធផលសម្រេចបានចាប់ពី៩០% ឡើងទៅ នឹងចាត់ទុកថា មានស្តង់ដាពេញលេញ

- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍អនុវត្តលទ្ធផលសម្រេចបានចាប់ពី៦៥% ដល់តិចជាង៩០% នឹងចាត់ទុកថា មានលក្ខណ:ស្តង់ដា
- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍អនុវត្តលទ្ធផលសម្រេចបានតិចជាង៦៥% នឹងចាត់ទុកថា មិនទាន់មានលក្ខណ:ស្តង់ដា។

មត្តេយ្យសិក្សាសហគមន៍ដែលទទួលលទ្ធផលចាប់ពីមានលក្ខណ:ស្តង់ដាឡើងទៅ មានសិទ្ធិទទួលបានការវាយតម្លៃ ដើម្បីទទួលថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា។

**ជំហានទី១៖** ភស្តុតាង ជាកំណត់ត្រាលទ្ធផលជាក់ស្តែងនៃលទ្ធផលសូចនាករ។

**ជំហានទី២៖** របៀបដាក់ពិន្ទុ ប្រសិនបើភស្តុតាងធៀបទៅនឹងកម្រិតផ្ទៀងផ្ទាត់សូចនាករ បានគ្រប់ចំណុចនិងត្រឹមត្រូវ នោះនឹងទទួលបានពិន្ទុតាមការកំណត់។

## ៥. តារាងស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍

| **ស្តង់ដាទី១៖ ការធ្វើផែនការនិងការពិនិត្យតាមដាន**<br>(ថ្នាក់មានផែនការនិងការពិនិត្យតាមដានដែលអាចជួយដល់ការអភិវឌ្ឍថ្នាក់រៀន) | | | |
|---|---|---|---|
| **សូចនាករ** | **កម្រិតផ្ទៀងផ្ទាត់សូចនាករ** | **ការផ្ទៀងផ្ទាត់លទ្ធផល** | |
| | | **ភស្តុតាង** | **ពិន្ទុ** |
| ១. ថ្នាក់រៀនមានផែនការអភិវឌ្ឍ | • ថ្នាក់រៀនមានស្ថិតិ ទិន្នន័យកុមារ (៣ ទៅក្រោម៦ឆ្នាំ) ត្រឹមត្រូវជាក់លាក់<br>• មានផែនការសកម្មភាពប្រចាំឆ្នាំស្របតាមទម្រង់ណែនាំ (តម្រូវការសម្ភារឧបទេស សម្ភារ:សម្រាប់តុបតែងថ្នាក់ និងសម្ភារ:ល្បែងក្នុងនិងក្រៅថ្នាក់ត្រូវដាក់ចូលទៅក្នុងផែនការផងដែរ ) | • | • |
| ២. ការិ.អ.យ.ក. ក្រុង ស្រុក ខណ្ឌ បានធ្វើការសង្កេតថ្នាក់យ៉ាងតិចមួយដងក្នុងមួយខែ | • មានកំណត់ហេតុ និងអនុសាសន៍របស់អ្នកសង្កេតនៅក្នុងសៀវភៅអនុសាសន៍របស់គ្រូដើម្បីវាយតម្លៃ | • | • |
| ៣. ការិ.អ.យ.ក. ក្រុង ស្រុក ខណ្ឌ បានផ្តល់ជំនួយដល់គ្រូបង្រៀនលើការងារបច្ចេកទេស ការផលិតសម្ភារឧបទេស បង្រៀននិងរៀន ការងាររដ្ឋបាលថ្នាក់ ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម | • មានកំណត់ហេតុ និងអនុសាសន៍របស់អ្នកសង្កេត សៀវភៅប្រជុំទទួលសម្ភារ ឯកសារ និងអនុសាសន៍របស់គ្រូ ដើម្បីតាមដានការិ. អ.យ.ក. ក្រុង ស្រុក ខណ្ឌ ដែលផ្តល់ជំនួយដល់គ្រូលើផ្នែកបច្ចេកទេសបង្រៀន ផ្តល់/ផលិតសម្ភារបង្រៀននិងរៀន ការងាររដ្ឋបាលថ្នាក់ ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម អនាម័យ សុខភាព ចំណីអាហារកុមារ | • | • |

| | | | |
|---|---|---|---|
| | និងផ្សេងៗ | | |
| ៤. មានការប្រជុំប្រចាំសប្តាហ៍ | • មានកត់ត្រាក្នុងកំណត់ហេតុ សៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ជាមួយសាលារៀន | • | • |
| ៥. ការប្រជុំមានភាពទៀងទាត់តាមការឯកភាពគ្នា | • បានប្រជុំបច្ចេកទេសរៀងរាល់ខែផ្អែកតាមផែនការរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ (ករណីថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅជិតមត្តេយ្យសិក្សារដ្ឋ គ្រូអាចចូលរួមប្រជុំជាមួយមត្តេយ្យសិក្សារដ្ឋតាមស្ថានភាពជាក់ស្តែង។ សូមអាន សេចក្តីណែនាំអនុវត្តប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ផ្អែកមត្តេយ្យសិក្សា) | • | • |
| ៦. ការប្រជុំភាគច្រើនផ្តោតលើខ្លឹមសារ ការអនុវត្តបទបញ្ជាបច្ចេកទេសបង្រៀន ការងាររដ្ឋបាល ការផលិតនិងប្រើប្រាស់សម្ភារឧបទេស | • មានកំណត់ហេតុ សៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសរបស់គ្រូមត្តេយ្យសិក្សា (ករណីនេះ ទទួលបានពិន្ទុលុះត្រាតែកំណត់ហេតុផ្តោតលើបច្ចេកទេសបង្រៀន) | • | • |

**ស្តង់ដារទី២ ៖ ការបង្រៀននិងរៀន**

(ការបង្រៀននិងរៀនមានប្រសិទ្ធភាព)

| **សូចនាករ** | **កម្រិតផ្ទៀងផ្ទាត់សូចនាករ** | **ការផ្ទៀងផ្ទាត់លទ្ធផល** | |
|---|---|---|---|
| | | **ភស្តុតាង** | **ពិន្ទុ** |
| ៧. គ្រូបង្រៀនមានផែនការបង្រៀន | • មានផែនការសកម្មភាពបង្រៀនប្រចាំថ្ងៃគ្រប់មុខវិជ្ជាតាមការណែនាំ និងមានការចុះហត្ថលេខាពីគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | • | • |
| ៨. គ្រូបង្រៀនប្រើផែនការបង្រៀន ជាប់លាប់គ្រប់មុខវិជ្ជា | • បានបង្រៀនតាមផែនការសកម្មភាពបង្រៀនប្រចាំថ្ងៃគ្រប់មុខវិជ្ជាទៅតាមកម្មវិធីសិក្សាប្រចាំថ្ងៃ និងខែនីមួយៗ | • | • |
| ៩. គ្រូបង្រៀនគោរពតាមកាលវិភាគ និងកម្មវិធីសិក្សាបានទៀងទាត់ | • បានបង្រៀនតាមកាលវិភាគនិងកម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំក្នុងមួយឆ្នាំសិក្សាមានចំនួន៩ខែ ចាប់ពីខែវិច្ឆិកា ដល់ខែសីហា ក្នុង១ឆ្នាំសិក្សា(ខែមេសា មិនមានកម្មវិធីសិក្សាសម្រាប់អនុវត្តទេ គ្រូត្រូវរំលឹកមេរៀនដែលនៅសេសសល់ពីខែមុនៗ) | • | • |

| | | | |
|---|---|---|---|
| | • ពេលវេលាបង្រៀនអាស្រ័យទៅលើការព្រមព្រៀងក្នុងកិច្ចសន្យារវាងគ្រូមត្តេយ្យសិក្សាសហគមន៍ និងក្រុមប្រឹក្សាឃុំ សង្កាត់ | | |
| ១០. គ្រូបង្រៀនមាននិងប្រើសម្ភារៈបង្រៀននិងរៀននៅពេលបង្រៀន | • មានសម្ភារៈបង្រៀន និងរៀនគ្រប់គ្រាន់តាមមុខវិជ្ជា ទាំងគ្រូនិងកុមារ<br>• ក្រោយពេលបង្រៀនចប់ គ្រូវយកសម្ភារៈទាំងនោះដាក់តាមជ្រុងថ្នាក់រៀន | • | • |
| ១១. គ្រូបង្រៀនបានរៀបចំថ្នាក់តាមស្តង់ដា | គ្រូបង្រៀនត្រូវរៀបចំថ្នាក់ ដោយរៀបចំឱ្យមានតាមគំរូដូចជា៖<br>ក. ការរៀបចំនៅតាមជញ្ជាំងខាងមុខ មានបាវចនាជាតិ ព្រះឆាយាល័ក្ខ តារាងផ្សេងៗដែលទាក់ទងនិងលិខិតបទដ្ឋានរបស់ក្រសួង កម្មវិធីសិក្សា និងកាលវិភាគ ក្តារខៀន សម្ភារឧបទេស និងតារាងសកម្មភាពប្រចាំថ្ងៃ<br>ខ. ការរៀបចំនៅតាមជញ្ជាំងសងខាង និងខាងក្រោយ មានផ្ទាំងរូបភាពដែលទាក់ទងនឹងការអប់រំ ផ្ទាំងរូបភាពសម្ភារឧបទេសបង្រៀនតាមមុខវិជ្ជាក្នុងកម្មវិធីសិក្សា ផ្ទាំងតាំងស្នាដៃកុមារ ពាក្យស្លោកដែលទាក់ទងនឹងការអប់រំ<br>គ. ការរៀបចំផ្ទៃលំហខាងលើ មានការចងខ្សែខ្វែងសម្រាប់ព្យួររូបភាពផ្សេងៗដូចជារូបសត្វ បន្លែ ផ្លែឈើ តួអក្សរ លេខ រាងធរណីមាត្រ<br>ឃ. ការរៀបចំនៅផ្ទៃខាងក្រោម មាន ទូរដាក់ និងតាំងសម្ភារៈ តុ កៅអីគ្រូនិងកុមារ<br>ង. ការរៀបចំជ្រុងថ្នាក់រៀនមាន៣ជ្រុងគឺជ្រុងអនាម័យ ជ្រុងសិល្បៈ និងជ្រុងសិក្សា | | |
| ១២. គ្រូបង្រៀនបានរៀបចំសៀវភៅ និងបញ្ជីផ្សេងៗតាមការណែនាំ | • សៀវភៅរដ្ឋបាលមាន៖<br>- សៀវភៅផែនការអភិវឌ្ឍថ្នាក់រៀន<br>- សៀវភៅផែនការសកម្មភាពបង្រៀនប្រចាំថ្ងៃ<br>- សៀវភៅប្រជុំបច្ចេកទេស និងការងារទូទៅ | • | • |

| | | | |
|---|---|---|---|
| | - សៀវភៅអនុសាសន៍<br>- សៀវភៅទទួលសម្ភារៈ និងឯកសារ<br>• បញ្ជីផ្សេងៗមាន៖<br>- បញ្ជីហៅឈ្មោះកុមារ<br>- បញ្ជីបញ្ជូនឈ្មោះកុមារឡើងថ្នាក់ទី១នៃសាលាបឋមសិក្សា<br>- បញ្ជីទំនាក់ទំនងមាតាបិតា(របាយការណ៍ប្រជុំជាមួយមាតាបិតា) | | |
| ១៣. ការធ្វើតេស្តទៀងទាត់ ៣ដង ក្នុង១ឆ្នាំ (សម្រាប់កុមារអាយុ៥ឆ្នាំ) | • បានធ្វើតេស្តទៀងទាត់ ស្របតាមឧបករណ៍តេស្តដោយអនុវត្ត ១ឆ្នាំ ៣ដង ចំពោះកុមារអាយុ៥ឆ្នាំ ដោយ៖<br>- លើកទី១ (សប្តាហ៍ទី២ ខែវិច្ឆិកា)<br>- លើកទី២ (សប្តាហ៍ទី២ ខែកុម្ភៈ)<br>- លើកទី៣ (សប្តាហ៍ទី២ ខែកក្កដា)<br>• បានសង្កេតដើម្បីវាស់សមត្ថភាពរបស់កុមារម្នាក់ៗតាមរយៈការធ្វើតេស្តត្រូវអនុវត្តទៅតាមសូចនាករទាំង១៨ រួចបំពេញក្នុងតារាងឧបករណ៍វាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ។ ត្រូវពិនិត្យតាមដានការមករៀន និងកិច្ចការក្នុងនិងក្រៅថ្នាក់របស់កុមារបានទៀងទាត់។<br>• បានយកលទ្ធផលតេស្តទៅរៀបចំផែនការក្នុងខែ ឬ ត្រីមាសបន្ទាប់ រួចរាយការណ៍ជូនអ្នកគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ | • | • |
| ១៤. គ្រប់គ្រូបង្រៀនមានកិច្ចសន្យាត្រឹមត្រូវនិងទទួលការបំប៉នដំបូង | • បានចុះកិច្ចសន្យាត្រឹមត្រូវជាមួយក្រុមប្រឹក្សាឃុំ សង្កាត់<br>• បានទទួលបំប៉នដំបូងតាមស្តង់ដាររយៈពេល៣៥ថ្ងៃ ស្តីពីចំណេះដឹងទូទៅការងារគ្រប់គ្រងរដ្ឋបាល ការងារបច្ចេកទេស និងការផលិតសម្ភារឧបទេសផ្នែកមត្តេយ្យសិក្សា<br>• គ្រូបង្រៀនមានក្រមសីលធម៌ ឧស្សាហ៍ និងព្យាយាម ទទួលខុសត្រូវ និងស្រឡាញ់កុមារ | • | • |
| ១៥. គ្រូបង្រៀនបំប៉នបន្តបាន | • បំប៉នបន្តបានពេញលេញឡើងវិញតាម | • | • |



ះ៍ចK

| | | | |
|---|---|---|---|
| ពេញលេញ | កម្មវិធីសិក្សាថ្មី មានរយៈពេល២០ថ្ងៃ ដោយផ្តោតលើកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីៗ | | |
| ១៦. ថ្នាក់មានគ្រូតាមនិយាម | • បានប្រើប្រាស់និយាមគ្រូបង្រៀន គឺ១ថ្នាក់ គ្រូ ១នាក់ | • | • |
| ១៧. ថ្នាក់មានសិស្សស្របតាមនិយាម | • ថ្នាក់រៀនមានសិស្សអាយុ៥ឆ្នាំ ក្នុង១ថ្នាក់ចន្លោះពី១៨ ដល់ ២៥នាក់ | • | • |
| ១៨. មាតាបិតាបានចូលរួមការអប់រំមាតាបិតា | • បានរៀបចំចងក្រងក្រុមមាតាបិតាកុមារនៅតាមថ្នាក់រៀន<br>• មាតាបិតារបស់កុមារបានចូលរួមក្នុងការអប់រំមាតាបិតា តាមផែនការរបស់មត្តេយ្យសិក្សាសហគមន៍<br>• មានកត់ត្រាក្នុងសៀវភៅកំណត់ហេតុរបស់គ្រូស្តីពីការចូលរួមជួបប្រជុំក្នុងការងារអប់រំមាតាបិតា | • | • |

## ស្តង់ដារទី៣ ៖ ការគ្រប់គ្រងទូទៅ

(ការគ្រប់គ្រងទូទៅមានដំណើរការនិងប្រសិទ្ធភាព)

| សូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | ការផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|
| | | ភស្តុតាង | ពិន្ទុ |
| ១៩. មានគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | • មានគណៈកម្មការគ្រប់គ្រងសម្រាប់ដំណើរការអភិវឌ្ឍលើការបង្រៀននិងរៀនរបស់កុមារ<br>• មានរៀបចំរចនាសម្ព័ន្ធរបស់គណៈកម្មការគ្រប់គ្រង | • | • |
| ២០. គណៈកម្មការមានដំណើរការ មានការប្រជុំទៀងទាត់និងជួយគាំទ្រដោះស្រាយបញ្ហាដែលបានឯកភាពគ្នា | • មានការប្រជុំទៀងទាត់តាមផែនការដើម្បីគាំទ្រ និងដោះស្រាយបញ្ហាដែលមាន ដូចជាដំណើរការទាក់ទងការអភិវឌ្ឍកុមារ ធនធានថវិកា សម្ភារៈ ការស្វែងរកគាំទ្រជំនួយសម្រាប់លើកកម្ពស់ដល់សុវត្ថិភាព សុខភាពអនាម័យ និងចំណីអាហាររបស់កុមារជាប្រចាំ<br>• មានកត់ត្រាពេលវេលា និងកំណត់ហេតុក្នុងសៀវភៅប្រជុំរបស់គ្រូ | • | • |
| ២១. មានធ្វើការវាយតម្លៃការ | • មានឧបករណ៍សង្កេតថ្នាក់មត្តេយ្យសិក្សា | • | • |

| | | | |
|---|---|---|---|
| អនុវត្តការងាររបស់គ្រូបង្រៀន ដោយមានការចូលរួមពីគ្រូបង្រៀន | សហគមន៍ស្របតាមឧបករណ៍តេស្តអំពីពេលវេលា និងខ្លឹមសារនៃការវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀន | | |
| ២២. ក្រុមប្រឹក្សាឃុំ សង្កាត់ធ្លាប់បានចុះពិនិត្យតាមដាននៅឆ្នាំមុនយ៉ាងតិចពី ៣-៥ដង | • មានកំណត់ហេតុពីពេលវេលាក្នុងសៀវភៅអនុសាសន៍របស់គ្រូដែលក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការគ្រប់គ្រងបានចុះពិនិត្យតាមដាននៅឆ្នាំមុន | • | • |
| ២៣. ជំនួយជាអាទិភាពដែលក្រុម ប្រឹក្សាឃុំ សង្កាត់ បានជួយជាពិសេស លើការងារគ្រប់គ្រងដំណើរការថ្នាក់រៀន | • មានកំណត់ហេតុក្នុងសៀវភៅអនុសាសន៍របស់គ្រូស្តីពីការជួយលើការងារគ្រប់គ្រងដំណើរការថ្នាក់រៀនដែលក្រុមប្រឹក្សាឃុំ សង្កាត់បានជួយជំរុញការចូលរៀន និងមករៀនរបស់កុមារទៀងទាត់ ជាពិសេសការផ្តល់ថវិកាប្រចាំខែ និងដោះស្រាយបញ្ហាផ្សេងៗទៀតដែលទាក់ទងការបង្រៀន និងរៀន | • | • |

## ស្តង់ដារទី៤ ៖ ការរាយការណ៍និងព័ត៌មានត្រឡប់

(ការរាយការណ៍និងព័ត៌មានត្រឡប់បានអនុវត្តតាមការណែនាំ)

| សូចនាករ | ភស្តុតាងផ្ទៀងផ្ទាត់សូចនាករ | ការផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|
| | | ភស្តុតាង | ពិន្ទុ |
| ២៤. គ្រូមត្តេយ្យសិក្សាសហគមន៍បានធ្វើរបាយការណ៍ និងបញ្ជីវត្តមានកុមារតាមគំរូពេញលេញផ្ញើទៅការិ. អ.យ.ក. ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាន់ពេលតាមការណែនាំ | • មានរបាយការណ៍ និងបញ្ជីវត្តមានកុមារតាមគំរូពេញលេញផ្ញើទៅការិយាល័យ អ.យ.ក. ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានទាន់ពេលវេលា១ខែម្តង | • | • |
| ២៥. របាយការណ៍មានទិន្នន័យត្រឹមត្រូវតាមតម្រូវការ និងមានបច្ចុប្បន្នភាព | • បានបញ្ចូលទិន្នន័យត្រឹមត្រូវតាមតម្រូវការទៅក្នុងរបាយការណ៍និងមានការប្រែប្រួលតាមពេលវេលាជាក់ស្តែង | • | • |
| ២៦. គ្រូបង្រៀនអាចរៀបរាប់បានថា ត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យលទ្ធផលសិក្សារបស់កុមារកើនឡើង | • បានរៀបរាប់ពីនីតិវិធី និងកត់ត្រាទុកពីលទ្ធផលសិក្សារបស់កុមារកើនឡើង (ករណីនេះ ទទួលបានពិន្ទុលុះត្រាតែ អាចរៀបរាប់បានយ៉ាងតិចពីរចំណុច) | • | • |

| | | | |
|---|---|---|---|
| ២៧. គ្រូបង្រៀនបានស្វែងយល់ពីលទ្ធផលសិក្សារបស់កុមារក្នុងថ្នាក់មត្តេយ្យសិក្សាសហគមន៍ផ្សេងទៀតក្នុងស្រុកតែមួយ | • មានកំណត់ត្រា និងយោបល់របស់គ្រូស្តីពីការស្វែងយល់លទ្ធផលសិក្សារបស់ថ្នាក់ខ្លួនដោយធៀបនឹងកុមារថ្នាក់ដទៃផ្សេងៗទៀតក្នុងស្រុកតែមួយពីការអភិវឌ្ឍលើចំណេះដឹងសុខភាពអនាម័យចំណីអាហារព្រមទាំងមានផែនការជួយជំរុញកុមាររបស់គាត់ (ករណីនេះទទួលបានពិន្ទុលុះត្រាតែ អាចរៀបរាប់ពីការស្វែងយល់អំពីលទ្ធផលសិក្សារបស់ថ្នាក់បាន) | • | • |

## ស្តង់ដារទី៥ ៖ ទីធ្លានិងសម្ភារៈល្បែងលេងក្រៅថ្នាក់

(ទីធ្លាលេងនិងល្បែងលេងក្រៅថ្នាក់មានភាពសមស្រប)

| សូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | ការផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|
| | | អស្តុតាង | ពិន្ទុ |
| ២៨. ទីធ្លាសម្រាប់កុមារលេងមានលក្ខណៈសមស្របទូលាយមានអនាម័យនិងមានសុវត្ថិភាព | • មានទីតាំងស្ថិតនៅលើដីសាធារណៈ<br>• មានដាក់ស្លាកឈ្មោះត្រឹមត្រូវ<br>• មានទីធ្លាខាងក្រៅទូលាយសម្រាប់កុមារលេងដោយសុវត្ថិភាព គ្មានវត្ថុបង្កគ្រោះថ្នាក់ដល់កុមារ<br>• មានធុងសម្រាម អនាម័យស្អាត<br>• មានរបង ក្លោងទ្វារ ដើមឈើជាម្លប់ និងសួនច្បារ | | |
| ២៩. ល្បែងក្រៅថ្នាក់មានលក្ខណៈសមស្រប មានសុវត្ថិភាព និងកុមារប្រើប្រាស់ជាប្រចាំ | • ល្បែងលេងក្រៅថ្នាក់គឺមានចាប់ពីមួយឡើងទៅ (ល្បែងលេងក្រៅថ្នាក់មាន ដូចជា ទោងបះបើក កងលូន ស្នូតោង កំណាត់ឈើដើរចុះឡើង ខ្សែពួរ ជាដើម)<br>• ល្បែងសម្រាប់កុមារលេងត្រូវដាក់នៅទីកន្លែងមានសុវត្ថិភាព មានអនាម័យ មានសោភ័ណ អាចឱ្យកុមារលេងជាប្រចាំ និងមិនបង្កគ្រោះថ្នាក់ដល់កុមារ ដូចជា ដាច់ខ្សែរបូតខ្ចៅ ច្រេះស៊ី ជាដើម( គ្រប់កន្លែងដែលមានល្បែងលេងក្រៅថ្នាក់ត្រូវក្រាលកៅស៊ូក្រាស់ទន់ ឬចាក់ដីខ្សាច់ ឬដាំស្មៅ) | • | • |
| ៣០. មានទឹកស្អាតសម្រាប់កុមារញ៉ាំ និងទឹកប្រើប្រាស់ | • មានទឹកស្អាតបរិភោគ និងទឹកសម្រាប់លាងដៃ<br>• មានធុងចម្រោះទឹកស្អាត កន្សែង និងពែងទឹកគ្រប់ចំនួនកុមារ (មានសញ្ញាសម្គាល់ | • | • |



ទីឹ

| | | | |
|---|---|---|---|
| | សម្រាប់ជាកម្មសិទ្ធិរបស់កុមារម្នាក់ៗ) | | |
| ៣១. មានបង្គន់ហើយប្រើប្រាស់ជាប្រចាំ | • មានបង្គន់នៅជិតកុមារអាចប្រើប្រាស់បានរាល់ថ្ងៃនិងស្អាតជាប្រចាំដោយបែងចែកសម្រាប់កុមារា កុមារីដោយឡែកពីគ្នា និងមានជម្រាលសម្រាប់សិស្សពិការ<br>• មានទឹកប្រើប្រាស់គ្រប់គ្រាន់ មានកន្លែងសម្រាប់លាងដៃ និងសាប៊ូ | • | • |

**ស្តង់ដាទី៦ ៖ សម្ភារៈប្រើប្រាស់និងសង្ហារិម**

(សម្ភារៈប្រើប្រាស់និងសង្ហារិមមានលក្ខណៈសមស្រប)

| សូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | ការផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|
| | | គស្តុតាង | ពិន្ទុ |
| ៣២. ថ្នាក់រៀនមានសង្ហារិមតាមស្តង់ដាអប្បបរមា | • មានតុ កៅអីគ្រូ និងកុមារធ្វើអំពីឈើ ជ័រ ឬដែកតាមលទ្ធភាពមូលដ្ឋាន<br>• តុ កៅអីកុមារមានទំហំសមស្របតាមវ័យរបស់កុមារ(ចៀសវាងការប្រើប្រាស់ តុ កៅអីសិស្សសាលាបឋមសិក្សា)<br>• តុ និងកៅអីអាចលើកដាក់បានតាមសកម្មភាពនីមួយៗនៃមុខវិជ្ជា<br>• មានក្តារខៀន<br>• មានតុសម្រាប់ដាក់តាំងសម្ភារគ្រប់តាមជ្រុងថ្នាក់រៀន<br>• មានទូសម្រាប់ដាក់សម្ភារឧបទេស និងឯកសារគោល និងឯកសារផ្សេងៗ | • | • |
| ៣៣. ថ្នាក់រៀនមានសម្ភារបង្រៀន និងរៀនតាមស្តង់ដាអប្បបរមា | • មានប្រអប់សង្គ្រោះបឋមប្រចាំថ្នាក់រៀន<br>• មានកម្មវិធីសិក្សាឯកសារគោលគ្រប់មុខវិជ្ជាតាមកម្មវិធីសក្សា<br>• មានសម្ភារឧបទេសគ្រប់មេរៀនតាមមុខវិជ្ជានីមួយៗនិងកម្មវិធីសិក្សា ប្រចាំខែ(មានវត្ថុធាតុដើមដែលរកតាមមូលដ្ឋាន ទិញពីទីផ្សារដើម្បីផលិតសម្ភារបង្រៀននិងរៀន និងសម្ភារល្បែងលេងនៅក្នុងថ្នាក់)<br>• រាល់សម្ភារដែលកុមារប្រើប្រាស់ត្រូវមានអនាម័យជាប្រចាំ<br>• មានសម្ភារសម្រាប់ពិនិត្យ និងតាមដានសុខភាពកុមារ ដូចជា ជញ្ជីងថ្លឹងទម្ងន់ | • | • |



ទ្ធK

| | | | |
|---|---|---|---|
| | ម៉ែត្រវាស់កម្ពស់ បញ្ជីតាមដានសុខភាព។ | | |

## ៦. ការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍តាមស្តង់ដារអប្បបរមា

### ៦.១ ឧបករណ៍វាយតម្លៃ

ស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍ជាឧបករណ៍សម្រាប់វាយតម្លៃដែលគ្រប់ភាគីពាក់ព័ន្ធដូចជា រដ្ឋបាលឃុំ សង្កាត់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមការងារអន្តរក្រសួង អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ស្របតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច ឬប្រព័ន្ធផ្សេងទៀត ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍។

| |
|---|
| *ស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍ មិនសំដៅទៅរកការដាក់ពិន័យឬទណ្ឌកម្ម ចំពោះគ្រូបង្រៀន សិស្សសហគមន៍ ឬអ្នកពាក់ព័ន្ធដែលបំពេញការងារមិនឆ្លើយតបស្តង់ដារទេ។ ប៉ុន្តែវាជារង្វាស់ឬមគ្គុទេសក៍ដឹកនាំអ្នកពាក់ព័ន្ធនានាឱ្យឈានទៅដល់ (ឬលើស)ស្តង់ដារ។ ប្រសិនបើមានស្តង់ដាណាមួយពុំទាន់សម្រេចនោះអ្នកពាក់ព័ន្ធមាន ឱកាសវាយតម្លៃស្ថានភាព និងកសាងមធ្យោបាយ ដើម្បីធ្វើឱ្យសម្រេច ឬលើសកម្រិត ស្តង់ដានាពេលអនាគត។* <br> *"ស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍ និងការវាយតម្លៃជាមធ្យោបាយ រីឯមត្តេយ្យសិក្សាសហគមន៍ជាគោលដៅក្នុងការកែលម្អ"។* |

### ៦.២ របបនៃការវាយតម្លៃ

ដើម្បីធានាថាការវាយតម្លៃស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ត្រូវអនុវត្តដូចខាងក្រោម៖

គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ត្រូវធ្វើស្វ័យវាយតម្លៃជារៀយៗក្នុងពេលដំណើរការបំពេញការងារតាមរយៈការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ឬតាមប្រព័ន្ធផ្សេងទៀត ដោយមានការជួយសម្របសម្រួលការងារបច្ចេកទេសពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ដើម្បីបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ដើម្បីបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានអប់រំកុមារតូច)។

នាយកដ្ឋានអប់រំកុមារតូចដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡាលើការងារអប់រំកុមារតូច ត្រូវរៀបចំវាយតម្លៃមត្តេយ្យសិក្សាសហគមន៍តាមយន្តការនិងនីតិវិធីជាធរមាន។

## ៦.៣ គំរូនៃការវាយតម្លៃ

ខាងក្រោមជាគំរូនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍៖

| **ស្តង់ដាទី១៖ ការធ្វើផែនការ និងការពិនិត្យតាមដាន**<br>(ថ្នាក់មានផែនការ និងការពិនិត្យតាមដានដែលអាចជួយដល់ការអភិវឌ្ឍថ្នាក់រៀន) | | | |
|---|---|---|---|
| **សូចនាករ** | **កម្រិតផ្ទៀងផ្ទាត់សូចនាករ** | **ការផ្ទៀងផ្ទាត់លទ្ធផល** | |
| | | **ភស្តុតាង** | **ពិន្ទុ** |
| ១. ថ្នាក់រៀនមានផែនការអភិវឌ្ឍ | • ថ្នាក់រៀនមានស្ថិតិ ទិន្នន័យកុមារ (៣ ទៅក្រោម៦ឆ្នាំ) ត្រឹមត្រូវជាក់លាក់<br>• មានផែនការសកម្មភាពប្រចាំឆ្នាំស្របតាមទម្រង់ណែនាំ (តម្រូវការសម្ភារឧបទេសសម្ភារៈសម្រាប់តុបតែងថ្នាក់ និងសម្ភារៈល្បែងក្នុងនិងក្រៅថ្នាក់ត្រូវដាក់ចូលទៅក្នុងផែនការផងដែរ ) | • មាន<br>• មាន | ១ |
| ២. ការិ.អ.យ.ក. ក្រុង ស្រុក ខណ្ឌ បានធ្វើការសង្កេតថ្នាក់យ៉ាងតិចមួយដងក្នុងមួយខែ | • មានកំណត់ហេតុ និងអនុសាសន៍របស់អ្នកសង្កេតនៅក្នុងសៀវភៅអនុសាសន៍របស់គ្រូដើម្បីវាយតម្លៃ | • មាន | ១ |
| ៣. ការិ.អ.យ.ក. ក្រុង ស្រុក ខណ្ឌ បានផ្តល់ជំនួយដល់គ្រូបង្រៀនលើការងារបច្ចេកទេស ការផលិតសម្ភារឧបទេសបង្រៀននិងរៀន ការងាររដ្ឋបាលថ្នាក់ ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម | • មានកំណត់ហេតុ និងអនុសាសន៍របស់អ្នកសង្កេត សៀវភៅប្រជុំទទួលសម្ភារ ឯកសារ និងអនុសាសន៍របស់គ្រូ ដើម្បីតាមដានការិ.អ.យ.ក. ក្រុង ស្រុក ខណ្ឌ ដែលផ្តល់ជំនួយដល់គ្រូលើផ្នែកបច្ចេកទេសបង្រៀន ផ្តល់/ផលិតសម្ភារបង្រៀននិងរៀន ការងាររដ្ឋបាលថ្នាក់ ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម អនាម័យ សុខភាព ចំណីអាហារកុមារ និងផ្សេងៗ | • មាន | ១ |
| ៤. មានការប្រជុំប្រចាំសប្តាហ៍ | • មានកត់ត្រាក្នុងកំណត់ហេតុ សៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ | • គ្មាន | ០ |



ទំ/៣៤

| | | | |
|---|---|---|---|
| | ជាមួយសាលារៀន | | |
| ៥. ការប្រជុំមានភាពទៀងទាត់តាមការឯកភាពគ្នា | • បានប្រជុំបច្ចេកទេសរៀងរាល់ខែផ្អែកតាមផែនការរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ (ករណីថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅជិតមត្តេយ្យសិក្សារដ្ឋ គ្រូអាចចូលរួមប្រជុំជាមួយមត្តេយ្យសិក្សារដ្ឋតាមស្ថានភាពជាក់ស្តែង។ សូមអានតាមសេចក្តីណែនាំអនុវត្តប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ផ្អែកមត្តេយ្យសិក្សា) | • មាន | ១ |
| ៦. ការប្រជុំភាគច្រើនផ្តោតលើខ្លឹមសារ ការអនុវត្តបទបញ្ញាបច្ចេកទេសបង្រៀន ការងាររដ្ឋបាល ការផលិតនិងប្រើប្រាស់សម្ភារឧបទេស | • មានកំណត់ហេតុ សៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសរបស់គ្រូមត្តេយ្យសិក្សា (ករណីនេះ ទទួលបានពិន្ទុលុះត្រាតែកំណត់ហេតុផ្តោតលើបច្ចេកទេសបង្រៀន) | • គ្មាន | ០ |

**លទ្ធផល៖** ទទួលបានពិន្ទុ៤ ក្នុងចំណោម៦ពិន្ទុនៃសូចនាករទាំង៦របស់ស្តង់ដាទី១ មានន័យថា ទទួលបាន ៦៦,៦៦%។

**វិធីគណនា**

- ស្តង់ដាទី១ មានសូចនាករចំនួន៦
- ក្នុងចំណោមសូចនាករទាំង៦ អនុវត្តបាន៤សូចនាករ

ដូចនេះ វិធីគណនាជាភាគរយគឺ៖ ចំនួនសូចនាករដែលអនុវត្តបាន(៤) ចែកនឹងចំនួនសូចនាករសរុប(៦) ហើយគុណនឹង១០០។

តាមលទ្ធផលនេះបង្ហាញថា ស្តង់ដាទី១ មត្តេយ្យសិក្សាសហគមន៍អនុវត្តបាន៦៦,៦៦% មានន័យថា មានលក្ខណៈស្តង់ដាសម្រាប់ស្តង់ដាទី១។

**រូបមន្តគណនាទូទៅ៖**

$$\text{លទ្ធផលសម្រេចបានជាភាគរយ} = \frac{\text{ចំនួនសូចនាករដែលអនុវត្តបាន}}{\text{ចំនួនសូចនាករសរុប}} \times ១០០$$

ឪCK

## ៧. សន្និដ្ឋាន

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ជាឧបករណ៍សម្រាប់វាយតម្លៃដែលគ្រប់ភាគីពាក់ព័ន្ធដូចជា រដ្ឋបាលឃុំ សង្កាត់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមការងារអន្តរក្រសួង អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ស្របតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច ឬប្រព័ន្ធផ្សេងទៀត ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា មត្តេយ្យសិក្សាសហគមន៍ នឹងខិតខំអភិវឌ្ឍខ្លួនឱ្យស្របតាមស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍នេះ ។